ធ៧-០៥-០៣ ស.រ.ណ.ន

# សារាចរណែនាំ
# ស្តីពី
# ការអនុវត្តន៍គណនេយ្យរូបិយវត្ថុចំរុះតាមប្លង់គណនីឯកភាព

សេចក្តីណែនាំនេះ ជាការណែនាំគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អំពីរបៀបធ្វើគណនេយ្យកម្មរូបិយវត្ថុច្រើនប្រភេទសម្រាប់ប្រតិបត្តិការរូបិយប័ណ្ណផ្សេងៗ ដែលរួមមាននីតិវិធីនៃការវាយតម្លៃឡើងវិញ និងគណនេយ្យកម្មប្រចាំថ្ងៃ សម្រាប់ចំណេញឬខាតពីការវាយតម្លៃឡើងវិញ ក៏ដូចជាការទទួលស្គាល់ស្ថានភាពប្តូរប្រាក់ពីការផ្តល់ឥណទានជារូបិយប័ណ្ណ និងការប្រាក់បង្គរជារូបិយប័ណ្ណ។

សេចក្តីណែនាំត្រូវអនុលោមតាមប្រកាសលេខធ៧-០០-៥០ ស្តីពី ដំណើរការគណនេយ្យកម្មសម្រាប់ប្រតិបត្តិការរូបិយប័ណ្ណ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០។

## គណនេយ្យកម្មរូបិយប័ណ្ណច្រើនប្រភេទ

ប្លង់គណនីឯកភាព ដែលបានអនុវត្តជាប្លង់គណនីឯកភាពមានរូបិយប័ណ្ណច្រើនប្រភេទ។ គណនីសៀវភៅធំ (General Ledger) នីមួយៗមានលេខកូដរូបិយប័ណ្ណមួយនៅខ្ទង់ចុងក្រោយ។ ប្រព័ន្ធលេខកូដនេះអនុវត្តចំពោះទ្រព្យសកម្ម ទ្រព្យអកម្ម ចំណូលនិងចំណាយ និងខ្ទង់ក្រៅតារាងតុល្យការ។ ដូច្នេះ ការចុះបញ្ជិកាប្រតិបត្តិការណាមួយ សុទ្ធតែបានចុះឥណពន្ធ និងឥណទានក្នុងគណនីសៀវភៅធំទៅតាមប្រភេទរូបិយប័ណ្ណនីមួយៗ។ ឧទាហរណ៍ ការផ្ទេរប្រាក់ចេញជាអឺរ៉ូ ដោយចុះឥណពន្ធគណនីរបស់អតិថិជនមួយអាចចុះបញ្ជីសាមញ្ញដូចខាងក្រោម ប្រសិនអតិថិជនមានគណនីចរន្តជាអឺរ៉ូ ៖

**ឥណពន្ធ** គណនីអតិថិជន ជាអឺរ៉ូ

**ឥណទាន** គណនី Nostro ជាអឺរ៉ូ

(មិនគិតកំរៃជើងសារ)

ករណីស្រដៀងគ្នា ឥណទានមានកាលកំណត់មួយ ជាថៃបាត អាចកត់ត្រា:

**ឥណពន្ធ** ឥណទានមានកាលកំណត់ជាបាតថៃ

**ឥណទាន** គណនីអតិថិជន ជាបាតថៃ

ដូចគ្នានេះដែរឥណទានមានកាលកំណត់មួយជាបាតថៃ អាចកត់ត្រាក្នុងទិន្នានុប្បវត្តិ "Journalized"

**ឥណពន្ធ** ឥណទានមានកាលកំណត់ជាបាតថៃ

**ឥណទាន** គណនីអតិថិជនជាបាតថៃ

ឧទាហរណ៍ខាងលើនេះ មិនមានជាប់ទាក់ទងនឹងការប្តូររូបិយប័ណ្ណទេ។ រាល់ហានិភ័យប្តូរប្រាក់ជាប្រាក់អឺរ៉ូ ឬជាបាតថៃ ខាងផ្នែកទ្រព្យសកម្មនិងទ្រព្យអកម្ម លែងកើតមានដោយសារបានចុះបញ្ជីទាំងខាងឥណពន្ធ និងខាងឥណទាន នៃទ្រព្យសកម្មផង និងទ្រព្យអកម្មផង។

ប៉ុន្តែ ប្រសិនបើអតិថិជនមានគណនីចរន្តជាប្រាក់ដុល្លារអាមេរិក ហើយចង់ឱ្យធនាគារផ្ទេរប្រាក់ជាអឺរ៉ូ ធនាគារនឹងប្តូរប្រាក់អឺរ៉ូ ទៅជាប្រាក់ដុល្លារអាមេរិក ហើយត្រូវចុះខាងឥណពន្ធនៃគណនីអតិថិជន។ ប្រតិបត្តិការនេះបង្កើតជាស្ថានភាពប្តូរប្រាក់ជាអឺរ៉ូ ធៀបជាមួយរូបិយប័ណ្ណគោលជាប្រាក់ដុល្លារអាមេរិក។ ការចុះបញ្ជីគណនេយ្យ គឺ:

**ឥណពន្ធ** គណនីអតិថិជន ជាដុល្លារអាមេរិក

**ឥណទាន** គណនីប្តូរប្រាក់សមមូលជាដុល្លារអាមេរិក

**ឥណពន្ធ** ស្ថានភាពប្តូរប្រាក់ ជាអឺរ៉ូ

**ឥណទាន** គណនី Nostro ជាអឺរ៉ូ

(រូបិយប័ណ្ណគោលជាដុល្លារអាមេរិក)

នៅក្នុងតារាងតុល្យភាពរូបិយប័ណ្ណច្រើនប្រភេទមួយ ប្រាក់ដុល្លារអាមេរិក និងប្រាក់អឺរ៉ូ នឹងមានសមតុល្យទាំងខ្ទង់ឥណពន្ធ និងឥណទាន។ ក្នុងការបង្ហាញនិងរាយការណ៍ការប្តូរប្រាក់ដុល្លារអាមេរិកនិងប្រាក់អឺរ៉ូជាប្រាក់រៀល ពុំបាននាំឱ្យមានចំណេញ ឬខាតក្នុងប្រតិបត្តិការប្តូរប្រាក់ ឬចំណេញ ឬខាតពីការប្តូរប្រាក់ទេ។

ក្នុងឧទាហរណ៍ខាងលើ ធនាគារមានស្ថានភាពប្តូរប្រាក់ជាប្រាក់អឺរ៉ូ ធៀបនឹងប្រាក់ដុល្លារអាមេរិក។ គណៈគ្រប់គ្រងធនាគារត្រូវកំណត់គោលនយោបាយផ្ទៃក្នុងអំពីដែនកំណត់នៃហានិភ័យប្តូរប្រាក់។ ស្ថានភាពប្តូរប្រាក់ត្រូវតែបានវាយតម្លៃឡើងវិញជាប្រចាំថ្ងៃ ឬគំលាតផ្សេងៗទៀតដោយប្រើអត្រាប្តូរប្រាក់ទីផ្សារ និងចំណេញ ឬខាតណាដែលចុះក្នុងរបាយការណ៍ចំណូល-ចំណាយ។ ចំណេញ និងខាតបានពីការវាយតម្លៃឡើងវិញនៃរូបិយប័ណ្ណរបស់ធនាគារ មិនត្រូវចុះក្នុងគណនីប្រាក់បម្រុងក្នុងតារាងតុល្យការទេ។

### គណនេយ្យរូបិយប័ណ្ណទ្វេភាគ

ថ្មីៗនេះ ធនាគារជាច្រើនប្រើប្រាស់គណនេយ្យកម្មរូបិយប័ណ្ណទ្វេភាគ ទោះបីបានយកប្លង់គណនីឯកភាពមកប្រើហើយក៏ដោយ ប្រការនេះមានរូបភាពពីរគឺ: ការអនុវត្តន៍មានរូបភាពពីរគឺ: ទី១ ធនាគារពុំមានគណនីទំនាក់ទំនងនៅក្រៅប្រទេសសម្រាប់ផ្ទេររូបិយប័ណ្ណ។ ឧបមាថា អតិថិជនធនាគារម្នាក់មានគណនីចរន្តជាប្រាក់ដុល្លារអាមេរិក ហើយគាត់បញ្ជាធនាគារិករបស់គាត់ឱ្យផ្ទេរប្រាក់ជាអឺរ៉ូ។ ក្នុងករណីនេះ ធនាគារិកបញ្ជូនស្ថានភាពប្តូរប្រាក់ទាំងស្រុងទៅធនាគារទំនាក់ទំនងរបស់ខ្លួននៅសហរដ្ឋអាមេរិក ហើយបញ្ជាធនាគារិក (នៅអាមេរិក) ឱ្យផ្ទេរប្រាក់អឺរ៉ូ និងកាត់ចេញពីគណនីរបស់គាត់ជាប្រាក់ដុល្លារអាមេរិក។ ធនាគារក្នុងស្រុកទទួលយកអត្រាប្តូរប្រាក់ដែលកាត់ចេញដោយធនាគារអាមេរិក ហើយធនាគារក្នុងស្រុកមិនមានស្ថានភាពប្តូរប្រាក់ទេ។ គុណវិបត្តិនៃរបៀបនេះគឺថាវាមានចំណាយខ្ពស់ចំពោះធនាគារក្នុងស្រុក និងអតិថិជនរបស់ខ្លួន។

រូបភាពទី២ ថាអតិថិជនមានគណនីចរន្តជាប្រាក់រៀល ប៉ុន្តែចង់ផ្ទេរប្រាក់ជាដុល្លារអាមេរិក។ ក្នុងករណីនេះ កិច្ចបញ្ជិកាគណនេយ្យក្នុងគណនីរូបិយប័ណ្ណទ្វេភាគត្រូវកត់ត្រា ដូចខាងក្រោម ៖

**ឥណពន្ធ** គណនីអតិថិជន ជារៀល

**ឥណទាន** គណនី Nostro ជាអឺរ៉ូ និងជារៀល (រូបិយប័ណ្ណទ្វេភាគ)

(មិនគិតកំរៃជើងសារ និងសន្មតថារូបិយវត្ថុគោលជារៀល)

ប្រាក់អឺរ៉ូនៅក្នុងគណនី Nostro និងប្រាក់សមមូលជារៀល នឹងប្រែប្រួលតាមតម្លៃទីផ្សារនៃប្រាក់អឺរ៉ូធៀបនឹងប្រាក់រៀល។ គ្រប់គ្រឹះស្ថានធនាគារគួរតែវាយតម្លៃរូបិយប័ណ្ណឡើងវិញធៀបនឹងរូបិយវត្ថុគោលយ៉ាងតិចបំផុតម្តងក្នុងមួយខែ ហើយយកចំណេញ ឬខាតទៅចុះក្នុងរបាយការណ៍ចំណូល-ចំណាយ។

**ខ្ទង់ចំណូល និងចំណាយពីរូបិយប័ណ្ណបរទេស**

មាត្រា៨នៃប្រកាសខាងលើចែងថា ចំណូលនិងចំណាយបង្ករជារូបិយប័ណ្ណ ដែលទាក់ទងដល់ការឱ្យខ្ចីនិងឥណទានជារូបិយប័ណ្ណ មូលបត្រ ឬប្រតិបត្តិការក្រៅតារាងតុល្យការ ត្រូវបានវាយតម្លៃឡើងវិញតាមអត្រាប្តូរប្រាក់ដល់ដៃ (Spot rate) ហើយត្រូវកត់ត្រាចូលក្នុងគណនីចំណេញ-ខាត។

ក្នុងប្រព័ន្ធគណនេយ្យកម្មរូបិយប័ណ្ណច្រើនប្រភេទខាងលើ ការងារនេះមានភាពងាយស្រួល។ នៅខែនីមួយៗ របាយការណ៍ចំណេញនិងខាតនឹងមានច្រើននៅពេលមានរូបិយវត្ថុផ្សេងៗនៅក្នុងធនាគារ។ ដើម្បីឱ្យមាត្រា ៨ មានប្រសិទ្ធភាព ធនាគារចាំបាច់គ្រាន់តែទទួលយកស្ថានភាពប្តូរប្រាក់រវាងចំណូលសុទ្ធ ដកចំណាយតាមរូបិយប័ណ្ណនីមួយៗ ហើយចុះបញ្ជីគណនី ៖

សន្មតថា មានចំណូលសុទ្ធជាបាតថៃ

**ឥណពន្ធ** ចំណូលជាបាតថៃ

**ឥណទាន** ស្ថានភាពប្តូរប្រាក់ ជាបាតថៃ

**ឥណពន្ធ** សមមូលជាដុល្លារអាមេរិក (សន្មត រូបិយប័ណ្ណគោលជាដុល្លារអាមេរិក)

**ឥណទាន** ចំណូលជាដុល្លារអាមេរិក

(អាស្រ័យដោយប្រតិបត្តិការនេះ ស្ថានភាពធនាគារនឹងវាយតម្លៃឡើងវិញនូវចំណូលពីការប្តូររូបិយប័ណ្ណទទួលបានពីការឱ្យខ្ចីជារូបិយប័ណ្ណរបស់ខ្លួន)

នៅក្នុងប្រព័ន្ធគណនេយ្យកម្មរូបិយប័ណ្ណទ្វេភាគ ការប្រាក់បង្ករមិនអាចធ្វើការវាយតម្លៃឡើងវិញដោយងាយស្រួលឡើយ នៅពេលណាការប្រាក់បង្ករត្រូវទទួលជារូបិយប័ណ្ណ និងចំណូលការប្រាក់ត្រូវបានចុះបញ្ជីតាមអត្រាចុះបញ្ជីដូចគ្នា។ ការវាយតម្លៃឡើងវិញណាក៏មិនមានផលប៉ះពាល់ដល់ចំនួនប្រាក់ចំណូលដែរ។

ភ្នំពេញ, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៥

**នាយកដ្ឋានត្រួតពិនិត្យ**

**ផាន់ ហូរ គិម វ៉ាដា**